ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា

ប្រចាំនៅទីក្រុងណាននីង

លេខ 0046 កពណក.ណន

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** **របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ២០១១**

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសគោរពជូនឯកឧត្តម **ទេសរដ្ឋមន្ត្រី** ជ្រាបដ៏ខ្ពង់ខ្ពស់នូវរបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ២០១១ ដូចតទៅ :

**ក. ការងារទំនាក់ទំនងភ្ញៀវ :**

-ជួបជាមួយ Nanning Tourism Bureau China មានបំណងបើកក្រុមហ៊ុនទេសចរណ៍ចិន-កម្ពុជា ។

-ទៅទស្សនកិច្ចមជ្ឈមណ្ឌល Nanning Hua Nan Cheng ។ មជ្ឈមណ្ឌលមានបំណងបង្កើតផ្សារលក់ទំនិញមកពីប្រទេសអាស៊ាន ដែលមានទីតាំងនៅក្បែរព្រលានយន្តហោះនៅណាននីង ។ ជំហ៊ានដំបូងមជ្ឈមណ្ឌលមានគំរោងផ្តល់ទីតាំងលក់ទំនិញចំនួន ៥000 $m^2$ សំរាប់កម្ពុជាដោយឥតគិតថ្លៃរយៈពេល៥ឆ្នាំដំបូង ។

-ជួបក្រុមហ៊ុន Eastern Land Investment Limited មានបំណងវិនិយោគទុននៅកម្ពុជាលើវិស័យធនាគារ ។

-ជួបក្រុមហ៊ុន Gold Wood Group មានបំណងវិនិយោគទុនក្នុងការបើកផ្សារលក់ទំនិញចិនទៅកម្ពុជា ។

-ជួបជាមួយ Guangxi Overseas Travel មានបំណងជំរុញភ្ញៀវទេសចរណ៍កម្ពុជា-ចិនឱ្យរីកចំរើន ។

-ចូលរួម Export-Oriented Agriculture Enterprizes Financial Instruments applied Remedial Class ដើម្បីផ្សព្វផ្សាយគោលនយោបាយវិនិយោគទុនលើវិស័យកសិកម្មនៅកម្ពុជា ។

-ទៅទស្សនកិច្ចផែស្ងួតនៅណាននីង ដែលរៀបចំឡើងដោយ Nanning Investment Bureau ។

-ចូលរួមសិក្ខាសាលានៅមន្ទីរកសិកម្មក្រុងណាននីង ដើម្បីអូសទាញវិនិយោគលើវិស័យកសិកម្មមកកម្ពុជា ។

-ជួបជាមួយមន្ទីរ    គយនៅណាននីង ដើម្បីស្វែងការគួរសម ។

## ខ. <u>សភាពការណ៍សេដ្ឋកិច្ចរវាងខេត្តក្វាងស៊ី_អាស៊ាន</u>

ខេត្តក្វាងស៊ីជាច្រកសេដ្ឋកិច្ចមួយដ៏ធំរវាង **ចិន_អាស៊ាន** ជាពិសេសរវាង **ចិន_កម្ពុជា** ។ ក្នុងរយៈពេល ៦ខែ ដើមឆ្នាំ២០១១នេះ ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងខេត្តក្វាងស៊ី-អាស៊ានមានការកើនឡើង ៣៩៣០.៨៨ លានដុល្លាអាមេរិក កើនបាន ៤៩.៥ % ។ ការនាំចេញមានទឹកប្រាក់ ២៧៥៦.៤៣ លានដុល្លាអាមេរិក កើនបាន ៥៦.២% ឯការនាំចូលវិញ មានចំនួន ១១៧៤.៤៥ លានដុល្លាអាមេរិក កើនបាន ៣៥.៧ % ។ ដោយឡែកការផ្លាស់ប្តូរពាណិជ្ជកម្មរវាងកម្ពុជា-ខេត្តក្វាងស៊ី ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១១នេះ សំរេចបាន ៩.០៣ លានដុល្លាអាមេរិក កើនបាន ១១៦.៧ % ។ ការនាំចេញពីខេត្តក្វាងស៊ីមកកម្ពុជាមានទឹកប្រាក់ ៨.៨៨ លានដុល្លាអាមេរិក កើនបាន ៣១.១ % ឯការនាំចូលពីកម្ពុជាមកខេត្តក្វាងស៊ី មានចំនួន ១៥ ម៉ឺនដុល្លាអាមេរិក ថយចុះចំនួន ៥៣.៨ % ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយ អនុគ្រោះ ។

សូម ឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ក្រុងណាននីង ថ្ងៃទី 5 ខែសីហា ឆ្នាំ២០១១

ទីប្រឹក្សាពាណិជ្ជកម្ម

**អ៊ុច គីមយ៉ុន**

ចម្លងជូន

- អគ្គកុងស៊ុលប្រចាំក្រុងណាននីង
- ឯកសារនិងកាលប្បវត្តិ

Add : #11Zhujin Road,China-ASEAN Business District,Nanning, Guangxi ,China Email: clo_cambodia@yahoo.com Tel/Fax: (0771)5389496